CEDAC

Weekly Bulletin (Week1) June, 2010

ព្រឹត្តិបត្រ ព័ត៌មានប្រចាំសប្តាហ៍

កសិកម្ម និងអភិវឌ្ឍន៍ជនបទ

## គោក្របីអ្នកភូមិនៅពោធិសាត់ងាប់ដោយមិនដឹងមូលហេតុ

*(វិទ្យុអាស៊ីសេរី ០៦ មិថុនា ២០១០)*

អ្នកភូមិកំរែង ស្ថិតក្នុងឃុំស្វាយស ស្រុកក្រគរ ខេត្តពោធិសាត់ឱ្យដឹងថា សត្វគោ និងក្របីអ្នកស្រុកជាង ២០ក្បាលបានងាប់ជាបន្តបន្ទាប់ដោយមិនដឹងពីមូលហេតុថាជំងឺអ្វីច្បាស់លាស់ឡើយ។ ប្រធានការិយាល័យបសុព្យាបាលស្រុកក្រគរលោកជួន ហ៊ិនមាន ប្រសាសន៍ថា ការងាប់គោក្របីរបស់អ្នកភូមិនេះគឺបណ្តាលមកពីជំងឺម្យ៉ាងហៅថា ជំងឺកង្វះជីវជាតិធ្ងន់ធ្ងរ។

## ឆ្នាំ២០១០ភ្នំពេញមានអគារកម្ពស់៣៨ជាន់

*(អេវីរីដេ ០៥ មិថុនា ២០១០)*

គម្រោងសំណង់អគារវឌ្ឍនៈកាពីតាលដែលមានកម្ពស់៣៨ជាន់និងមានតម្លៃជាង ១៥០លានដុល្លារអាមេរិកនឹងលេចចេញរូបរាងក្នុងខែ កញ្ញាឆ្នាំ២០១២ ខាងមុខនៅកណ្តាលរាជធានីភ្នំពេញ ។ ពិធីចុះហត្ថលេខាលើកិច្ចសន្យាសាងសង់អគារកម្ពស់ ៣៨ជាន់ក្នុងកិច្ចសន្យាសាងសង់រវាងក្រុមហ៊ុន Vattanak Properties Cp.,Ltd និងក្រុមហ៊ុន POSCO E&C LTD របស់ប្រទេសចិនបានធ្វើឡើងកាលពីសៀវថ្ងៃពុធទី ២ខែមិថុនាឆ្នាំ ២០១០ក្រោមអធិបតីភាពលោកសុខអានឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ លោកស្រីឈុនលាងបណ្ណា ធិការក្រុមហ៊ុន Vattanak Properties Cp.,Ltd និយាយថាក្រុមហ៊ុនបានបង្កើនទុន វិនិយោគរហូតដល់ ១៥០លាន ដុល្លារអាមេរិកដើម្បី កសាងអគារនេះ ។ លោកស្រីបណ្ណាធិការ ក្រុមហ៊ុនបានបញ្ជាក់ថាគម្រោងសាងសង់អគារនេះនឹងត្រូវបញ្ចប់ជាស្ថាពរតាមកាលបរិច្ឆេទកំណត់នៅខែ កញ្ញាឆ្នាំ២០១២ ។ អគារវឌ្ឍនៈកាពីតាលនេះ បានសាងសង់លើផ្ទៃដី ១២៨.000ម៉ែត្រការ៉េមាន៣៨ជាន់មានកម្ពស់ ១៨៣,៨0 ម៉ែត្រនិងចំណតរថយន្តក្រោមដី ៤ជាន់ដែល នឹងផ្តល់នូវទីតាំង សម្រាប់សកម្មភាព ពាណិជ្ជកម្មគ្រប់ ប្រភេទដោយរួមបញ្ចូលទាំងធនាគារការិយាល័យផ្សារទំនើប ។ល ។

## អ្នកបើកម៉ូតូជាង១០ម៉ឺនមានប័ណ្ណបើកបរ

*(អេវីរីដេ ០៥ មិថុនា ២០១០)*

អ្នកប្រើប្រាស់ម៉ូតូសព្វថ្ងៃនេះបើតាមតួលេខម៉ូតូដែលបានចុះបញ្ជីនៅក្រសួងសាធារណការគឺមានជាង ១លាននាក់តែអ្នកដែលមានប័ណ្ណបើកបរតាមច្បាប់ចរាចរណ៍ដែលកំពុងតែអនុវត្តសព្វថ្ងៃនេះទើបតែមានជាង ១0ម៉ឺននាក់ទេ។ បើគិតទាំងអ្នកមានប័ណ្ណបើកបររថយន្តផងទើបបានប្រមាណជា ៥0ម៉ឺននាក់ ។ មានន័យថានៅលើដងផ្លូវសព្វថ្ងៃនេះមានអ្នកធ្វើចរាចរណ៍ដោយមិន

ចេះច្បាប់ ចរាចរណ៍ ច្រើនជាង៥០ភាគរយ។លោក ព្រាបច័ន្ទវិបុលប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការ និយាយឱ្យដឹងកាលពីថ្ងៃទី៤មិថុនាឆ្នាំ ២០១០ថាប័ណ្ណបើកបរជាង៩ម៉ឺនប័ណ្ណត្រូវបានផ្តល់ឱ្យអ្នកបើកបរម៉ូតូនៅទូទាំងប្រទេសក្នុងរយៈពេល៤ខែ ដើមឆ្នាំ២០១០ នេះបន្ទាប់ពីអ្នកទាំង នោះបានចូលរៀនច្បាប់ចរាចរណ៍និងប្រឡងយកប័ណ្ណបើកបររួច។ ប័ណ្ណបើកបរ ដែលបានចេញឱ្យ អ្នកបើកបរម៉ូតូនៅទូទាំង ប្រទេសមកទល់ពេលនេះបានចំនួនជាង ១០ម៉ឺនប័ណ្ណហើយ ។ ការផ្តល់ប័ណ្ណបើកបរម៉ូតូបានច្រើននៅក្នុងរយៈពេលចុងក្រោយនេះត្រូវបានប្រភពខាងលើបញ្ជាក់ឱ្យដឹងថា ដោយសារមានការជំរុញខ្លាំងពីមន្ត្រីជំនាញ នគរបាលចរាចរ និងមានកិច្ចសហការ ពីអាជ្ញាធរមូលដ្ឋានឱ្យប្រជាពលរដ្ឋដែល ប្រើប្រាស់ម៉ូតូនាំគ្នាទៅរៀនច្បាប់ចរាចរណ៍និងប្រឡងយកប័ណ្ណបើកបរម៉ូតូដោយនៅខេត្តខ្លះគេបានចុះបង្រៀនច្បាប់ចរាចរណ៍ដល់មូលដ្ឋានតែម្តង។

## ដំណាំកាហ្វេផលិតផលកាហ្វេនៅកម្ពុជាមិនមានការគាំទ្រ

*(វិទ្យុវីអូអេ ០៤ មិថុនា ២០១០)*

យោងតាមមន្ត្រីនៃក្រសួងកសិកម្មបានឱ្យដឹងថា ផ្ទៃដីដែលអាចដាំកាហ្វេបាននៅក្នុងប្រទេសកម្ពុជា មានច្រើនពាន់ហិកតា ប៉ុន្តែរហូតមកដល់ពេលនេះផ្ទៃដីដែលបានកំពុងដាំកាហ្វេមានតែ ២៣២ហិកតាតែប៉ុណ្ណោះ គឺនៅខេត្តរតនៈគិរីចំនួន ១០០ហិកតា មណ្ឌលគិរី ៤០ហិកតា កោះកុង ៤៩ហិកតា កំពត ១ហិកតា កំពង់ចាម ២ហិកតា កំពង់ស្ពឺ ១៣ហិកតា និងកំពង់ចាម ២៦ហិកតា។ លោកគង់ ពុទ្ធារ៉ា ប្រធាននាយកដ្ឋានស្ថិតិព័ត៌មាននៃក្រសួងពាណិជ្ជកម្មឱ្យដឹងថា នៅឆ្នាំ ២០០៩ ប្រទេសកម្ពុជាបាននាំចូលកាហ្វេពីក្រៅចំនួន ៥៣៣៦៩ គីឡូក្រាម ដែលគិតជាទឹកប្រាក់ប្រហែលជាង ៩៥០៥៩ដុល្លារ។

## ប្រទេសម្ចាស់ជំនួយសន្យាផ្តល់ប្រាក់ ១១០០លានដុល្លារដល់កម្ពុជា

*(វិទ្យុអាស៊ីសេរី ០៣ មិថុនា ២០១០)*

លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច គាត ឈន់បានប្រកាសជាផ្លូវការថា តំណាងប្រទេសម្ចាស់ជំនួយអន្តរជាតិនានាបានសន្យាផ្តល់ប្រាក់ជំនួយសរុបចំនួន ១១០០លានដុល្លារអាមេរិក សម្រាប់កិច្ចអភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្នាំ ២០១០នេះ។ ក្នុងនោះប្រទេសជប៉ុននៅតែជាប្រទេសលំដាប់ថ្នាក់លេខមួយ ក្នុងការផ្តល់ជំនួយច្រើនជាងបណ្តាប្រទេសនានាដល់កម្ពុជាដែលមានទឹកប្រាក់រហូតប្រមាណ ១៣០លានដុល្លារអាមេរិក។

## រដ្ឋាភិបាលប្រកាសប្រឆាំងអំពើពុករលួយ

*(អេវីរីដេ ០៣ មិថុនា ២០១០)*

សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែនកាលពីថ្ងៃព្រហស្បតិ៍បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការប្រយុទ្ធប្រឆាំងនឹង មន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងអំពើពុករលួយនិងបានហៅ អំពើនេះថាជា " ជំងឺដ៏គ្រោះថ្នាក់មួយ"។ ថ្លែងក្នុងពិធីចែក សញ្ញាបត្រដល់និស្សិតមកពីសាលាភូមិន្ទ រដ្ឋបាលកាលពីថ្ងៃទី ៣ ខែមិថុនាសម្តេចនាយក រដ្ឋមន្ត្រីបានបង្ហាញថាមានមន្ត្រីមួយចំនួនតូចប៉ុណ្ណោះក្នុងស្ថាប័នរដ្ឋដែលបានប្រព្រឹត្តអំពើពុករលួយតែមន្ត្រីដទៃទៀតពុំបានធ្វើដូចពួកគេឡើយ ។ សម្តេចហ៊ុនសែនមានប្រសាសន៍នៅវិទ្យាស្ថានជាតិអប់រំថា"ខ្ញុំមានសុទិដ្ឋិនិយមថាយើងនៅតែមានលទ្ធភាពប្រឆាំងនឹងជំងឺដ៏គ្រោះថ្នាក់មួយនេះ។ អំពើពុករលួយនឹង

បំផ្លាញស្ថាប័នដ៏សំខាន់នេះ" ។ សម្តេចហ៊ុនសែនបានថ្លែងបន្តថាក្នុងជួរកងកម្លាំងនគរបាល យោធានិង ស្ថាប័នរដ្ឋាភិបាលមនុស្សមិនច្រើនទេដែល ប្រព្រឹត្តអំពើពុករលួយគឺមានតែមួយចំនួនតូចប៉ុណ្ណោះហើយរដ្ឋាភិបាលនឹងជំរុញឱ្យ មន្ត្រីដទៃទៀតរួមគ្នាប្រយុទ្ធប្រឆាំង ។យើងមានច្បាប់សម្រាប់ដាក់ទោសពួកគេ។ សម្តេចមាន ប្រសាសន៍ថា "អ្នកដែល ប្រព្រឹត្តអំពើ ពុករលួយធ្វើដោយ សម្ងាត់តែត្រូវ ដឹងថាអ្នកដទៃ ដែលកំពុង ធ្វើការជា មួយអាចរក វិធីណាមួយដើម្បីដឹងរឿងនេះបាន" ។

## កូរ៉េផ្តល់ឥណទានជិត៣០លានដុល្លារធ្វើផ្លូវ

*(អេវីរីដេ ០៣ មិថុនា ២០១០)*

មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឱ្យដឹងថាធនាគារនីហ័រណអាហ័រណេកូរ៉េបានផ្តល់ឥណទានចំនួន ២៩,៩៤លានដុល្លារ ដល់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់គម្រោងកែលម្អផ្លូវជាតិនៅតាមខេត្តភាគពាយ័ព្យ កម្ពុជានៃមហាអនុតំបន់ទន្លេមេគង្គ។ ធនាគារអភិវឌ្ឍន៏អាស៊ី(អេឌីប៊ី)ក៏បានផ្តល់ឥណទានសម្បទានចំនួន ១៦,២៦លានដុល្លារដែរសម្រាប់គម្រោងការធ្វើផ្លូវនៅភាគពាយ័ព្យនេះ។ លោកឧបនាយករដ្ឋមន្ត្រីគាតឈន់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង លោកដុងស៊ូគីមប្រធានធនាគារនីហ័រណអាហ័រណ កូរ៉េបានចុះហត្ថលេខាលើកិច្ចព្រម ព្រៀងស្តីពីការផ្តល់ឥណទាននេះកាលពីថ្ងៃទី១មិថុនាឆ្នាំ ២០១០នៅក្រុងភ្នំពេញ។ និយាយពីឥណទានរបស់សាធារណរដ្ឋកូរ៉េបើតាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឱ្យដឹងថាបូកនឹងកិច្ចព្រមព្រៀងឥណទានថ្ងៃនេះ ផងឥណទានរបស់សាធារណរដ្ឋ កូរ៉េឱ្យមកកម្ពុជាមានចំនួន៩លើកហើយដោយសរុបជាទឹកប្រាក់មានចំនួនកើនដល់ប្រមាណ ២៤៩លានដុល្លារអាមេរិក ។

## ស្ពានអាកាស២ខ្សែស្ថាបនាលើផ្លូវរុស្ស៊ី

*(អេវីរីដេ ០៣ មិថុនា ២០១០)*

រាជធានីភ្នំពេញនឹងស្ថាបនាស្ពានអាកាស២ខ្សែទៀតនៅលើកំណាត់មហាវិថីសហព័ន្ធរុស្ស៊ីព្រមគ្នាតែម្តង។ ខ្សែទី១ រត់កាត់លើមហាវិថី សហព័ន្ធរុស្ស៊ីពីផ្លូវខាងលិចក្រសួងអភិវឌ្ឍន៏ជនបទទៅ កាន់តំបន់បឹងកក់និង ខ្សែទី២រត់លើបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ីកាត់លើផ្លូវលេខ ៥៩៨ពីអតីតតោ២ទៅខាងលិចស្ថានីយប្រេងសូគីម៉ិចត្រង់ភ្លើងស្តុបពេទ្យព្រះសង្ឃ។ មន្ត្រីជំនាញ បានប្រាប់រស្មី កម្ពុជាថ្ងៃទី០២ មិថុនាថារាជធានីភ្នំពេញនឹងស្ថាបនាស្ពានអាកាស២ខ្សែនេះនៅលើកំណាត់មហាវិថីសហព័ន្ធរុស្ស៊ីព្រមគ្នាតែម្តង។ ការកសាងស្ពាន អាកាសថ្មីពីរនេះ នឹងធ្វើឡើងនៅក្រោយពេលសម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានអាកាសក្បាលថ្នល់នាថ្ងៃទី២៤ខែមិថុនា២០១០ខាងមុខនេះ។ ស្ពានអាកាសរំលងក្តាន់២មានប្រវែង៤៧០ម៉ែត្រទទឹង១៥,២ម៉ែត្រនិងកម្ពស់៥,២ម៉ែត្រ។ ចំណែកឯស្ពានអាកាសនៅ ស្តុបពេទ្យ ព្រះសង្ឃមិន ទាន់បានកំណត់ ប្រវែងបណ្តោយទទឹង និងកម្ពស់នៅ ឡើយទេដោយសារតំបន់នោះ ធំហើយវែង ទាមទារឱ្យ ធ្វើការសិក្សាល្អិតល្អន់ថែមទៀត។

## មន្ត្រីជាន់ខ្ពស់កម្ពុជានិយាយពីបញ្ហានាំចេញផលិតផលកសិកម្ម

*(វិទ្យុអូស្ត្រាលី ០២ មិថុនា ២០១០)*

កាសែតភ្នំពេញប៉ុស្តិ៍បានរាយការណ៍ថា លោកម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិយាយថា កង្វះខាងរោងចក្រកែច្នៃវត្ថុធាតុដើម បានធ្វើឱ្យមានការខាតបង់ប្រាក់ដល់ប្រទេសជាតិនៅពេលដែលមានការធ្វើពាណិជ្ជកម្មផលិតផលកសិកម្មកើតឡើង។ លោកថា ប្រទេសថៃ និងប្រទេសវៀតណាមកំពុងស្រូបយកផលប្រយោជន៍ពីប្រទេសកម្ពុជានៅរដូវប្រមូលផលកសិកម្ម ជាពិសេសក្នុងវិស័យឧស្សាហកម្មគ្រាប់ស្វាយចន្ទី និងដំឡូងមី។ លោកថា ប្រទេសវៀតណាមបាននាំចេញគ្រាប់ស្វាយចន្ទីរបស់កម្ពុជា ចំនួន ១ម៉ឺន ៦ពាន់តោន ហើយសម្រាប់កាកែច្នៃដំឡូងមីនោះ ប្រទេសទាំងពីរខាងលើ បង្កើតនូវតំលៃបានរហូតដល់ទៅមួយជាពីរ នៅពេលដែលគេលក់ផលិតផលសំរេចនោះទៅកាន់ប្រទេសចិន និងបណ្តាប្រទេសដ៏ទៃទៀត។

## គ្រោះថ្នាក់ចរាចរណ៍ឆ្នាំ ២០០៩ធ្វើអោយរដ្ឋាភិបាលខាងបង់ ២៤៨លានដុល្លារ

*(កោះសន្តិភាព ០២ មិថុនា ២០១០)*

យោងតាមការសិក្សារបស់អង្គការជនពិការអន្តរជាតិបែលហ្សិកបានរកឃើញថា ក្នុងឆ្នាំ ២០០៩ គ្រោះថ្នាក់ចរាចរណ៍បានធ្វើអោយប្រទេសកម្ពុជាខាតបង់ថវិកាអស់ប្រមាណ ២៤៨លានដុល្លារ។ របាយការណ៍ឆ្នាំ ២០០៩ឱ្យដឹងថា គ្រោះថ្នាក់ចរាចរណ៍មានចំនួន ១២.៥៣៨ករណី ជនរងគ្រោះសរុប ២១.៥១៩នាក់ ដែលក្នុងនោះមានជនរងគ្រោះស្លាប់ចំនួន ១.៧១៧នាក់ រងរបួសធ្ងន់ធ្ងរចំនួន ៧.០២២នាក់ និងរបួសស្រាល ១២.៧៨០នាក់ ដោយមិនគិតដល់បន្សល់ទុកកូនកំព្រា ស្ត្រីមេម៉ាយ ជិការភាព និងសេកនាដកម្មជាច្រើនទៀត។

## សហគ្រិនវ័យក្មេងមានវត្តមានកាន់តែច្រើនឡើងនៅក្នុងពិភពជំនួញ

*(វិទ្យុអូបារាំង ០២ មិថុនា ២០១០)*

ក្នុងរយៈពេលមួយទស្សវត្សចុងក្រោយនេះយុវជន និងយុវនារីដែលមានសញ្ញាប័ត្រជាន់ខ្ពស់មានវត្តមានកាន់តែច្រើនឡើងនៅក្នុងពិភពជំនួញ។ មិនត្រឹមតែប៉ុណ្ណោះ ការប៉ាន់ស្មានខ្លះបានបង្ហាញថានាពេលបច្ចុប្បន្ននេះគឺមានវត្តមានសហគ្រិនវ័យក្មេងជាង ៦០%។

## កុមារកំព្រាដោយសារមេរោគអេដស៍អាចនឹងមានចំនួន ១០៦.០០០នាក់នៅឆ្នាំ ២០១១

*(រស្មីកម្ពុជា ០២ មិថុនា ២០១០)*

មន្ត្រីជាន់ខ្ពស់របស់ក្រសួងសុខាភិបាលឱ្យដឹងថា កុមារកំព្រាដោយសារមេរោគអេដស៍អាចនឹងមានចំនួន ១០៦.០០០នាក់នៅឆ្នាំ ២០១១។

## ពាណិជ្ជកម្មរវាងកម្ពុជា និងសិង្ហបុរីកើនឡើងខ្ពស់ក្នុងឆ្នាំ ២០០៩

*(វិទ្យុអូស្ត្រាលី ០១ មិថុនា ២០១០)*

រដ្ឋាភិបាលប្រទេសកម្ពុជានិយាយថា ពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសិង្ហបុរីបានកើនឡើងដល់ទៅ ៨៤ភាគរយនៅក្នុងឆ្នាំ ២០០៩។ កាសែតភ្នំពេញប៉ុស្តិ៍រាយការណ៍ថា ផ្អែកលើតួលេខពីក្រសួងពាណិជ្ជកម្ម កំណើនពាណិជ្ជកម្មនោះបណ្តាលមកពីការនាំខ្សាច់ទៅកាន់ប្រទេសសិង្ហបុរី។ ពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសិង្ហបុរីបានកើនឡើងដល់ ១ពាន់ ១៨០លានដុល្លារអាមេរិក ដោយការនាំចេញរបស់ប្រទេសសិង្ហបុរីបានកើនឡើង ៤១ភាគរយ និងការនាំចេញរបស់ប្រទេសកម្ពុជាបានកើនឡើងដល់ទៅ ២៧៥ភាគរយ។

## សហភាពអឺរ៉ុបផ្តល់លុយជាង ២.៧លានដុល្លារសម្រាប់គម្រោងប្រែប្រួលអាកាសធាតុនៅខ្មែរ

*(ដើមអំពិល ០១ មិថុនា ២០១០)*

សេចក្តីប្រកាសព័ត៌មានរបស់សហភាពអឺរ៉ុបនៅថ្ងៃនេះឱ្យដឹងថា កម្ពុជាបានទទួលលុយជាង ២.៧លានដុល្លារសហរដ្ឋអាមេរិក សម្រាប់គម្រោងប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសពីសហភាពមួយនេះ។ សេចក្តីប្រកាសបានឱ្យដឹងទៀតថា ប្រទេសមួយចំនួនទៀតនៅក្នុងទ្វីបអាស៊ីក៏បានទទួលជំនួយពីសហភាពអឺរ៉ុបផងដែរសម្រាប់គំរោងប្រែប្រួលអាកាសធាតុ ដែលរួមមានប្រទេសបង់ក្លាដេស ប្រទេសម៉ាឌីវជាដើម។

## អាជ្ញាធរចែកធុងចម្រោះទឹកស្អាតឱ្យអ្នកភូមិនៅបាត់ដំបង

*(វិទ្យុអាស៊ីសេរី ០១ មិថុនា ២០១០)*

ប្រជាពលរដ្ឋនៅភូមិក្បាលតោល ឃុំកោះជីវាំង ស្រុកឯកភ្នំទទួលបានធុងចម្រោះទឹកស្អាតចំនួន ៦៦៥ធុង ពីអាជ្ញាធរខេត្តបាត់ដំបង បន្ទាប់ពីមានការរាតត្បាតយ៉ាងសាហាវពីជំងឺរាករូសដែលបណ្តាលមកពីកង្វះទឹកស្អាតប្រើប្រាស់ប្រចាំថ្ងៃ។ គិតចាប់តាំងពីពាក់កណ្តាលខែមេសា រហូតដល់ថ្ងៃទី ១០ ឧសភាអ្នកភូមិក្បាលតោលចំនួន ២០នាក់បានស្លាប់ដោយសារជំងឺរាកក្អួត។

## ជំរឿនមន្ត្រីចុងក្រោយនៅក្រសួងកសិកម្ម

*(អេវីរីដេ ០១ មិថុនា ២០១០)*

ប្រតិបត្តិការជំរឿនមន្ត្រីរាជការក្នុងក្រសួងកសិកម្មសម្រាប់រយៈពេល៣ថ្ងៃបានចាប់ផ្តើមកាលពីថ្ងៃទី៣១ឧសភាម្សិលមិញ។នេះជាជំរឿនមន្ត្រីរាជការក្រសួងចុងក្រោយរបស់រដ្ឋាភិបាលក្នុងគោលបំណង ដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឱ្យបានហ្មត់ចត់ និងដើម្បីធានា ឱ្យបានប្រសិទ្ធ ភាពការងារនិងធ្វើឱ្យ មានគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ។ ក្នុងរយៈពេល ៣ថ្ងៃមានមន្ត្រីថ្នាក់កណ្តាលរបស់ក្រសួងនេះចំនួន ២៦៩៨នាក់និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ១១៤នាក់នឹងត្រូវធ្វើជំរឿន។ យោងតាមប្រសាសន៍របស់លោកច័ន្ទ សារុនរដ្ឋមន្ត្រីក្រសួងកសិកម្ម ប្រតិបត្តិការជំរឿន មន្ត្រីរាជការស៊ីវិលមានបីផ្នែក។ ទីមួយគឺការរាប់

មន្ត្រីរាជការ នឹងធ្វើឡើងជាលក្ខណៈរូបវ័ន្តហើយតម្រូវឱ្យមន្ត្រីរាជការមានវត្តមានដោយផ្ទាល់ នៅតាមទីកន្លែងកំណត់សម្រាប់ការធ្វើប្រតិបត្តិការជំរឿន។ ទី២-ការចែក អត្តសញ្ញាណប័ណ្ណថ្មីដល់មន្ត្រី រាជការស៊ីវិល គ្រប់រូបដែលមានវត្តមានក្នុងពេលរាប់សម្រាប់ប្រើប្រាស់ជាផ្លូវការនិងទីបីការបំពេញព័ត៌មានសម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ ដែលតម្រូវឱ្យមន្ត្រីរាជការគ្រប់រូបបំពេញតាមកម្រងសំណួររៀបចំដោយគណៈកម្មការជំរឿន។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវការជំនួយ

*(វីអូអេ ៣១ ឧសភា ២០១០)*

រដ្ឋសភាបានអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល ៥ឆ្នាំដែលមានតម្លៃទឹកប្រាក់ជាង ៦ពាន់លានដុល្លារអាមេរិកសំដៅជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្នាំ ២០០៩-២០១៣ត្រូវការចំណាយជាង ៦.២៧៨លានដុល្លារអាមេរិក ដែលនឹងទទួលបានពីប្រភពធនធានទាំងក្នុងស្រុក និងក្រៅប្រទេស។

ផែនការនេះបានផ្តោតទៅលើការពង្រឹងស្ថិរភាពនយោបាយ ការគោរពសិទ្ធិមនុស្ស អភិបាលកិច្ចល្អ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការស្តារ និងកសាងបណ្តាញផ្លូវជាតិសំខាន់ៗ ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការកាត់បន្ថយភាពក្រីក្រ សមត្ថភាពស្ថាប័ន និងសមត្ថភាពធនធានមនុស្ស។

## ខេត្តរតនគិរីក្នុង១ឆ្នាំបាត់បង់ព្រៃឈើអស់ ២០០០ហិកតា

*(កោះសន្តិភាព ២៧ ឧសភា ២០១០)*

លោកប៉ាវ ហមផាន អភិបាលខេត្តរតនគិរីបានថ្លែងថា នៅក្នុងខេត្តរតនៈគិរីទាំងមូលមាន ៩ស្រុក-ក្រុង និងមានប្រជាជន ៣ម៉ឺនគ្រួសារ ស្មើនឹងជាង ១៥ម៉ឺននាក់ ភាគច្រើនជាជនជាតិភាគតិច ម្លោះហើយការកាប់ទន្ទ្រានព្រៃឈើយកដីធ្វើស្រែចំការវិលជុំច្រើនកើតមាន។ ក្នុងមួយឆ្នាំ ព្រៃឈើបានបាត់បង់ប្រមាណ ២០០០ហិកតា។